# របាយការណ៍ស្ដីពីការត្រៀមរៀបចំសម្រាប់ឆ្នាំរាំងស្ងួត នៅកម្ពុជា

ផែនការយុទ្ធសាស្ត្រស្ដីពីការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ បានផ្ដល់ជាមូលដ្ឋានសម្រាប់ពង្រឹងភាពធន់ទៅនឹងគ្រោះរាំងស្ងួត និងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ។ លើសពីនេះទៀត មានគោលនយោបាយនិងផែនការជាក់លាក់សម្រាប់វិស័យ ដែលដោះស្រាយលើទិដ្ឋភាពជាក់លាក់ នៃការគ្រប់គ្រងផលប៉ះពាល់ និងការកសាងភាពធន់ទៅនឹងគ្រោះរាំងស្ងួត រយៈពេលវែង។

គ្រោះរាំងស្ងួតត្រូវបានដោះស្រាយតាមរយៈការគ្រប់គ្រងធនធានទឹក។ រាជរដ្ឋាភិបាលកម្ពុជា ដោយមានផែនការយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យធនធានទឹកនិងឧតុនិយម (២០១៣-២០១៧) បានខិតខំប្រឹងប្រែងអនុវត្តឆ្ពោះទៅរកការកែលម្អបណ្ដាញឧតុនិយមនិងជលសាស្ត្រក្នុងប្រទេស និងផ្ដល់ព័ត៌មានទាន់ពេលវេលាស្ដីពីផលប៉ះពាល់ដោយធាតុអាកាស និងមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន រួមទាំងគ្រោះរាំងស្ងួត។ ផែនការនេះក៏ផ្ដល់ផងដែរសម្រាប់ការកសាង មូលទិន្នន័យទឹកក្រោមដីថ្នាក់ជាតិ ដើម្បីប៉ាន់ប្រមាណធនធាន សម្រាប់ប្រព័ន្ធធារាសាស្ត្រកសិកម្ម។ ឈានទៅរកទីបញ្ចប់នេះ អ៊ីវ៉តឺ (eWater) ប្រទេសអូស្ត្រាលី បានគាំទ្រគំនិតផ្ដួចផ្ដើមជាច្រើនលើមូលដ្ឋានគ្រប់គ្រងទឹក ដោយផ្អែកលើបទពិសោធន៍របស់អូស្ត្រាលី ក្នុងការគ្រប់គ្រងគ្រោះរាំងស្ងួត។ ផែនការនេះក៏រួមបញ្ចូល ទាំងការស្តារប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច និងមធ្យម ដើម្បីឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធិភាព ក្នុងអំឡុងពេលមានគ្រោះរាំងស្ងួត។

ការដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងគ្រោះរាំងស្ងួតដែលកើតមានញឹកញាប់ និងធ្ងន់ធ្ងរ រាជរដ្ឋាភិបាលមានគោលបំណងបង្កើនសមត្ថភាពថ្នាក់ជាតិ ផ្នែកជីវបច្ចេកវិទ្យា។ ផែនការអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ផ្ដល់អាទិភាពដល់ការអភិវឌ្ឍគ្រាប់ពូជធន់នឹងអាកាសធាតុ ពូជស្រូវមានគុណភាពខ្ពស់ រួមជាមួយការកែលម្អគ្រាប់ពូជសម្រាប់សាកវប្បកម្ម ដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម និងកែលម្អប្រព័ន្ធផលិតកម្ម បសុសត្វ។

ក្រៅពីគំនិតផ្ដួចផ្ដើម ដឹកនាំដោយថ្នាក់ជាតិ មានគម្រោងជាច្រើនដែលឧបត្ថម្ភគាំទ្រដោយម្ចាស់ជំនួយ និងបានរួមចំណែកដោយផ្ទាល់ដល់ការកសាងភាពធន់ទៅនឹងគ្រោះរាំងស្ងួត។ ការពង្រឹងព័ត៌មានអាកាសធាតុ និងប្រព័ន្ធផ្ដល់ព័ត៌មានជាមុន ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយភាពធន់នឹងអាកាសធាតុ (២០១៥-២០២០) នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងកសាងសមត្ថភាពស្ថាប័ន សម្រាប់ការតាមដានត្រួតពិនិត្យ ធាតុអាកាស និងអាកាសធាតុ។ គម្រោងនេះកំពុងត្រូវបានអនុវត្តដោយ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលទទួលបានការគាំទ្រថវិកាពីមជ្ឈមណ្ឌលបរិស្ថានពិភពលោក។ ជាមួយការវិភាគ ការធ្វើគម្រូ និងផ្សព្វផ្សាយព័ត៌មានអំពីនិន្នាការ អាកាសធាតុ និងការផ្ដល់ប្រឹក្សាផ្នែកអាកាសធាតុ គម្រោងនេះក៏ធ្វើការឆ្ពោះទៅរកការអភិវឌ្ឍប្រព័ន្ធប្រកាសឱ្យដឹងមុន ។

គម្រោងផ្សេងទៀត គឺជាផ្នែកមួយនៃការគ្រប់គ្រង និងការកាត់បន្ថយ មុខសញ្ញាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត របស់មហាអនុតំបន់ទន្លេមេគង្គ (២០១៣-២០២០) ដែលត្រូវបានឧបត្ថម្ភគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ក្នុងន័យនេះ ការកសាងសហគមន៍ធន់នឹងគ្រោះមហន្តរាយលើកទី២ មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងគ្រោះរាំងស្ងួត និងទឹកជំនន់នៅក្នុងខេត្តពោធិ៍សាត់ ដោយពង្រឹងសមត្ថភាព សម្រាប់ការព្យាករណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត និងការប្រកាសឱ្យដឹងមុន ការកែលំអហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក និងការកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួតនៅមូលដ្ឋានសហគមន៍។ យុទ្ធសាស្រ្ត គឺដើម្បីបង្កើនសមត្ថភាព ភាពជាអ្នកដឹកនាំ និងបង្កើនកិច្ចសម្របសម្រួលស្ថាប័នថ្នាក់ជាតិ សម្រាប់ការធ្វើសមាហរណកម្ម ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ពួកគេ។ វាក៏មានគោលបំណង ជួយដល់ស្ថាប័ននៅថ្នាក់ក្រោមជាតិ និងជនបទឱ្យបង្កើតយុទ្ធសាស្រ្ត កាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយ ប្រសិទ្ធភាព និងបង្កើនភាពធន់ តាមរយៈការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមមូលដ្ឋានសហគមន៍។

គម្រោងមួយដែលមានចំណងជើងថា "កសាងការអនុវត្តកសិកម្មប្រកបដោយភាពធន់ ដោយសមាហរណកម្មព័ត៌មានភូមិសាស្រ្ត សម្រាប់ការតាមដានត្រួតពិនិត្យលើវិស័យកសិកម្ម នៅអាងទន្លេមេគង្គក្រោមៈ ការផ្ដោតលើល័ក្ខខ័ណ្ឌស្រូវ" កំពុងត្រូវបានអនុវត្តនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។ គម្រោងនេះមានគោលបំណងពង្រឹងសន្តិសុខស្បៀង និងជីវភាពរស់នៅទប់ទល់នឹងអាកាសធាតុនិងគ្រោះមហន្តរាយផ្សេងៗ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មាន តាមដានត្រួតពិនិត្យតាមប្រព័ន្ធឱ្យដីថល មុនពេលមានបញ្ហាអាកាសធាតុ។ ដោះស្រាយបញ្ហាឆ្លងដែនទាក់ទងនឹងទឹក និងបង្កើតការព្យាករណ៍ផលិតកម្ម ផ្អែកលើភូមិសាស្ត្រ ដោយប្រើប្រព័ន្ធតាមដានត្រួតពិនិត្យដំណាំយថាផល (CropWatch Cloud)។ ដោយមានការគាំទ្រពីអង្គការអេស្កាប់ (ESCAP) វិទ្យាស្ថាននៃការចាប់សញ្ញាពីចម្ងាយ និងផែនដីឱ្យដីថល (RADI) នៃបណ្ឌិត្យសភាវិទ្យាសាស្រ្តចិន បានផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេស អំពីប្រព័ន្ធតាមដានត្រួតពិនិត្យដំណាំយថាផល (CropWatch Cloud) ដែលសម្របទៅតាមតម្រូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដូចមានឈ្មោះ បង្ហាញក្នុងប្រព័ន្ធនេះ (http://cloud.cropwatch.com.cn) គឺជាវេទិកាតាមដានត្រួតពិនិត្យដំណាំយថាផល ដែលផ្ដល់សេវាកម្មព័ត៌មាន ផ្អែកកសិកម្ម និងក្សេត្រសាស្រ្តអាស្រ័យអាកាសធាតុ។ វាអាចមានការផ្លាស់ប្ដូរទម្រង់ ក្នុងការតាមដានត្រួតពិនិត្យដំណាំ ដោយផ្ដើមចេញពីឧបករណ៍ និងទិន្នន័យទៅជាសេវាកម្មព័ត៌មាន ផ្ដល់ដល់អ្នកប្រើប្រាស់។ គម្រោងនេះក៏រួមបញ្ចូលទាំងការពង្រឹងសមត្ថភាព ក្នុងការប្រើប្រាស់ឧបករណ៍ស្មាតហ្វូន ដែលបំពាក់ឧបករណ៍ (GIS-Video-GPS) ដើម្បីប្រមូលសំណាកភូមិសាស្រ្ត លើប្រភេទដំណាំ និងការប្រើប្រាស់ទិន្នន័យនៅលើតំបន់ផលិតកម្មកសិកម្មសំខាន់ៗនៅថ្នាក់ក្រោមជាតិ ដើម្បីក្រិតតាមខ្នាតផែនទី ដំណាំ និងម៉ូដែលផែនទីដំណាំស្រូវ នៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យដំណាំយថាផល CropWatch Cloud សម្រាប់ប្រទេសកម្ពុជា។

*__ប្រភព__: របាយការណ៍អេស្កាប់ (ESCAP) ឆ្នាំ២០១៩ លើប្រធានបទ "ត្រៀមរៀបចំសម្រាប់ឆ្នាំរាំងស្ងួត" (ទំព័រ ៤០-៤១)*